# មកនិយាយអំពីការយកកូនចេញ៖
## សំណួរដែលបានសួរជាញឹកញាប់

ការិយាល័យផ្នែកសុខភាពរបស់ស្ត្រី របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (Los Angeles County Department of Public Health, Office of Women's Health)



តើការយកកូនចេញគឺជាអ្វី?



ការយកកូនចេញ (Abortion) គឺជា**ការបញ្ចប់ការមានផ្ទៃពោះដែលកំពុងតែមាន**។ នៅពេលដែលការមានផ្ទៃពោះបញ្ចប់ទៅដោយធម្មជាតិ នោះគឺហៅថា**ការបាត់បង់គត៌ដោយឯកឯង (spontaneous abortion) ឬជាការរលូតកូន (miscarriage)**។ ជាទូទៅ ពាក្យថាការយកកូនចេញនេះប្រើប្រាស់សម្រាប់**ការធ្វើឱ្យបាត់បង់គត៌ (induced abortion)** ហើយជាពេលដែលបុគ្គលម្នាក់**ធ្វើសកម្មភាពមួយដើម្បីបញ្ចប់ការមានផ្ទៃពោះ។ នៅក្នុងការសន្ទនានេះ យើងខ្ញុំគឺកំពុងនិយាយអំពីការធ្វើឱ្យបាត់បង់គត៌។**



តើការយកកូនចេញមានសុវត្ថិភាព ដែរឬទេ?



ការយកកូនចេញគឺ**មានសុវត្ថិភាពយ៉ាងខ្លាំង និងកើតមានជាទូទៅផងដែរ**។ ហានិភ័យផ្សេងៗនៃការមានផលវិបាកពាក់ព័ន្ធទៅនឹងការយកកូនចេញគឺ**មានកម្រិតទាបជាងហានិភ័យផ្សេងៗពាក់ព័ន្ធទៅនឹងការផ្ទៃពោះរហូតដល់គ្រប់ខែ ចំនួន 14 ដង**។ នៅក្នុងសហរដ្ឋអាមេរិក ការមានផ្ទៃពោះចំនួនប្រមាណ 18% គឺបញ្ចប់ទៅដោយការយកកូនចេញ។



តើការយកកូនចេញនៅក្នុងរដ្ឋ California ស្របនឹងច្បាប់ ដែរឬទេ?



មែនហើយ **ការយកកូនចេញគឺស្របនឹងច្បាប់**។ ជាការពិតទៅនោះ **ការយកកូនចេញគឺជាសិទ្ធិចាំបាច់មួយនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃរដ្ឋ California ផងដែរ**។ មនុស្សទាំងឡាយអាចយកកូនចេញនៅក្នុងរដ្ឋ California បាន **ដោយមិនគិតអំពីអាយុ ឬស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ ឬក៏ថាតើពួកគេរស់នៅខាងក្នុង ឬខាងក្រៅរដ្ឋនេះ នោះទេ**។



តើការយកកូនចេញមានរបៀបខុសៗគ្នាអ្វីខ្លះ?



**ការយកកូនចេញដោយប្រើប្រាស់ថ្នាំពេទ្យ (Medication abortion)** គឺជាការបញ្ចប់ការមានផ្ទៃពោះ**ដោយប្រើប្រាស់ថ្នាំគ្រាប់ប្រភេទ mifepristone និងប្រភេទ misoprostol**។ ជាធម្មតា មានការទទួលលេបថ្នាំគ្រាប់ទាំងនេះ**នៅខាងក្រៅបន្ទប់ពិនិត្យសុខភាព** ហើយអនុញ្ញាតឱ្យការយកកូនចេញនោះធ្វើទៅម្តងបន្តិចៗ។ **ការយកកូនចេញដោយការបឺតយកចេញ (Aspiration abortion)** គឺជាការបញ្ចប់ការមានផ្ទៃពោះនៅពេលដែល**អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាញយកគត៌ពីក្នុងស្បូនចេញមក**។ ការយកកូនចេញបែបនេះ**ធ្វើទៅនៅក្នុងគ្លីនិកផ្នែកថែទាំសុខភាពមួយ**។

COUNTY OF LOS ANGELES
Public Health



តើថ្នាំពន្យារកំណើតបែបបន្ទាន់ និង ថ្នាំពេទ្យសម្រាប់យកកូនចេញ (ការយកកូនចេញដោយប្រើប្រាស់ថ្នាំពេទ្យ) មានភាពខុសគ្នាយ៉ាងដូចម្តេច?



មានការប្រើប្រាស់**ថ្នាំពន្យារកំណើតបែបបន្ទាន់ (Emergency contraception) បន្ទាប់ពីការរួមភេទ** ដើម្បីទប់ស្កាត់ការមានផ្ទៃពោះ។ ផ្ទុយទៅវិញ **ការយកកូនចេញដោយប្រើប្រាស់ថ្នាំពេទ្យ (medication abortion) បញ្ចប់ការមានផ្ទៃពោះដែលកំពុងតែមាន**។



តើការយកកូនចេញបង្កើនហានិភ័យនៃការកើតមានជំងឺមហារីកសុដន់ ឬជំងឺមហារីកផ្សេងទៀត ដែរឬទេ?



ទេ ការស្រាវជ្រាវ**មិនបានរកឃើញថាមានការទាក់ទងគ្នា**រវាងការយកកូនចេញ និងជំងឺមហារីកក្នុងទម្រង់ណាមួយនោះទេ។



តើការយកកូនចេញប៉ះពាល់ដោយផ្ទាល់ទៅលើការអាចមានកូននាពេលអនាគត ឬការមានផ្ទៃពោះនាពេលអនាគត ដែរឬទេ?



ទេ **មិនមានភស្តុតាង**ណាមួយដែលថាការយកកូនចេញកាត់បន្ថយសមត្ថភាពក្នុងការមានផ្ទៃពោះ (ការអាចមានកូន/fertility) ឬបង្កើនហានិភ័យនៃការរលូតកូន ឬក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ការមានផ្ទៃពោះនាពេលអនាគត ក្នុងរបៀបណាមួយនោះទេ។ មហាវិទ្យាល័យគ្រូពេទ្យឯកទេសផ្នែកសម្ភពនិងរោគស្ត្រីរបស់អាមេរិក (American College of Obstetrics and Gynecologists) បានពិនិត្យមើលភស្តុតាងទាំងឡាយឡើងវិញ ហើយ **មិនបានរកឃើញថាមានការទាក់ទងគ្នារវាងការយកកូនចេញនិងការកាត់បន្ថយការអាចមានកូន ឬក៏រវាងការយកកូនចេញនិងបញ្ហាផ្សេងៗអំពីការមានផ្ទៃពោះនាពេលអនាគតនោះទេ**។



តើការយកកូនចេញធ្លាប់ដែលមានការបង្ហាញថាបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ដែរឬទេ?



**ទេ ការយកកូនចេញតាមការចង់បាន មិនបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្តនោះទេ**។ មនុស្សទាំងឡាយអាចជួបប្រទះទៅនឹងអារម្មណ៍ផ្សេងៗដូចជា ទុក្ខព្រួយ ឬការសោកសៅក្រោយពីការយកកូនចេញរួច ប៉ុន្តែមនុស្សភាគច្រើនមានអារម្មណ៍យ៉ាងលើសលប់ថាមានការធូរស្រាល។ **ចំណុចនេះគឺជាការពិតសម្រាប់ការយកកូនចេញ ដែលកើតមានឡើងក្នុងពេលណាក៏ដោយ ក្នុងអំឡុងពេលមានផ្ទៃពោះ ទាំងក្នុងពេលភ្លាមៗក្រោយការយកកូនចេញ និងក្នុងពេលជាច្រើនឆ្នាំក្រោយមក។** មនុស្សមួយចំនួនក៏អាចនឹងជួបប្រទះទៅនឹងអារម្មណ៍ថាមានកំហុស ឬមានការវាយតម្លៃទុកជាមុនអំពីការយកកូនចេញ ដោយសារតែ **ការរំពឹងទុករបស់ក្រុមគ្រួសារ ឬផ្នែកវប្បធម៌ ឬក៏ផ្នែកសាសនា ផងដែរ**។



តើខ្ញុំអាចយកកូនចេញបានយ៉ាងដូចម្តេច?



ព័ត៌មានបន្ថែមអំពីការយកកូនចេញ ហើយនិងបញ្ជីពេញលេញមួយអំពីសេវាកម្មផ្នែកការយកកូនចេញនៅក្នុងខោនធី Los Angeles និងនៅទូទាំងប្រទេស គឺអាចរកឃើញបាននៅលើគេហទំព័រ របស់ការិយាល័យផ្នែកសុខភាពរបស់ស្ត្រី (OWH) តាមរយៈ:

AbortionSafeHaven.LACounty.gov